# អនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី០៣/១២/២០១៤
# ស្តីពីការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនឱ្យនិរន្តរភាពនិងប្រសិទ្ធភាពក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ។

**មាត្រា ២.**

អនុក្រឹត្យនេះមានគោលដៅដើម្បីកំណត់នូវ ៖

- ភារកិច្ចកំណត់របស់មន្ត្រីរាជការសម្រាប់ការងាររដ្ឋបាល និងការងារបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- បែបបទ និងនីតិវិធីប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ដើម្បីបំពេញបន្ថែមលើសេវាបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលជួបការខ្វះគ្រូបង្រៀនជាមន្ត្រីរាជការ
- ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួបសម្រាប់មន្ត្រីរាជការដែលបានអនុវត្ត ដោយពោលពេញភារកិច្ចកំណត់របស់ខ្លួនរួចហើយ
- ប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការដែលបានអនុវត្តភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប
- ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការបង្រៀនតាមកិច្ចសន្យា និងការអនុវត្តភារកិច្ចកំណត់ ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប ។

**មាត្រា ៣**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការដែលបំពេញការងាររដ្ឋបាល មន្ត្រីរាជការជាគ្រូបង្រៀនជាប់កិច្ចសន្យា និងការគ្រប់គ្រងសេវាបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈរបស់

ក្រសួងយុវជន និងកីឡា ។

**មាត្រា ៤.**

ពាក្យប្រើប្រាស់ក្នុងអនុក្រឹត្យនេះមាននិយមន័យកំណត់ដូចខាងក្រោម ៖

- ភារកិច្ចកំណត់ សំដៅដល់ភារកិច្ចដែលត្រូវបានកំណត់ឱ្យមន្ត្រីរាជការគ្រូបង្រៀន ឬមន្ត្រីរាជការបំពេញការងាររដ្ឋបាល អនុវត្តផ្អែកលើមុខងារ និងថេរៈវេលាកំណត់ដោយអនុក្រឹត្យនេះ
- ភារកិច្ចបន្ថែម សំដៅដល់ការងារដែលត្រូវប្រគល់បន្ថែមឱ្យមន្ត្រីរាជការដែលមានភារកិច្ចកំណត់ម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សមួយថ្នាក់ ក្នុងពេលផ្សេងតាមកាលវិភាគប្រចាំថ្ងៃនៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- ភារកិច្ចថ្នាក់គួប សំដៅដល់ការងារដែលប្រគល់ឱ្យគ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សពីរក្រុម ឬ បីក្រុម ដែលមានកម្រិតខុសៗគ្នានៅក្នុងបន្ទប់រៀនតែមួយ ក្នុងថេរៈវេលាតែមួយ តាមកាលវិភាគទន់ភ្លន់ដែលរៀបចំដោយគ្រូផ្ទាល់ និងបានឯកភាពពីគណៈគ្រប់គ្រងសាលា
- មន្ត្រីរាជការសំដៅដល់មន្ត្រីរាជការផ្នែករដ្ឋបាល និងមន្ត្រីរាជការផ្នែករដ្ឋបាល និងមន្ត្រីរាជការផ្នែកបង្រៀននៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- គណៈគ្រប់គ្រងសាលា សំដៅដល់គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលដឹកនាំដោយនាយក ឬនាយិកាសាលា និងមាននាយករង ឬនាយិការងសាលាជាជំនួយ ។

## ជំពូកទី ២

## ភារកិច្ចកំណត់របស់មន្ត្រីរាជការសម្រាប់ការងាររដ្ឋបាល និងការងារបង្រៀន

**មាត្រា ៥.**

មន្ត្រីរាជការដែលបម្រើការងារនៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តកាតព្វកិច្ចការងាររយៈពេល ៨(ប្រាំបី) ម៉ោងក្នុងមួយថ្ងៃ និងប្រាំថ្ងៃក្នុងមួយសប្តាហ៍ ឬរយៈពេល ៤០(សែសិប) ម៉ោងក្នុងមួយសប្តាហ៍ ផ្អែកលើការចាត់ចែងរបស់គណៈគ្រប់គ្រងសាលា អនុលោមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយត្រូវធានាឱ្យបាននូវនិរន្តរភាព និងប្រសិទ្ធភាពទាំងការងាររដ្ឋបាល ទាំងការងារបង្រៀន ។

**មាត្រា ៦**

មន្ត្រីរាជការជាគ្រូបង្រៀនដែលទទួលបន្ទុកការងារបង្រៀន មានភារកិច្ចកំណត់ដូចខាងក្រោម ៖

- ផ្តល់ការបង្រៀនជាក់ស្តែង និងពិតប្រាកដដល់សិស្សនៅតាមថ្នាក់ និងកម្រិតសិក្សា
- បំពេញការងារពាក់ព័ន្ធគ្រប់យ៉ាងសម្រាប់ថ្នាក់រៀនដែលខ្លួនទទួលបន្ទុក ។

**មាត្រា ៧.**

រយៈពេលនៃការអនុវត្តភារកិច្ចកំណត់របស់មន្ត្រីរាជការជាគ្រូបង្រៀនដែលទទួលបន្ទុកការងារបង្រៀនត្រូវបានកំណត់ដូចខាងក្រោម ៖

សម្រាប់ថ្នាក់ទី ១ ទី២ និងទី៣

- គ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់ផ្នែកបង្រៀនសិស្សមួយថ្នាក់ ក្នុងថេរៈវេលាមួយពេលនៃកាលវិភាគប្រចាំថ្ងៃនៅក្នុងគ្រឹះស្ថានសិក្សា គឺមួយថ្ងៃបង្រៀន ៥(ប្រាំ)ម៉ោងសិក្សា និង៥(ប្រាំ) ថ្ងៃក្នុងមួយសប្តាហ៍ ឬបង្រៀន២៥(ម្ភៃប្រាំ) ម៉ោងសិក្សាក្នុងមួយសប្តាហ៍ នៅពេលព្រឹក ឬនៅពេលរសៀល
- ក្រៅពីរយៈពេលដែលត្រូវបំពេញសម្រាប់ការបង្រៀន គ្រូបង្រៀន ត្រូវបំពេញការងារពាក់ព័ន្ធសម្រាប់ថ្នាក់រៀនដែលខ្លួនទទួលបន្ទុកក្នុងក្របខ័ណ្ឌនៃរយៈពេលដែលបានកំណត់ក្នុងមាត្រា ៥ និងមាត្រា ៦នៃអនុក្រឹត្យនេះ

សម្រាប់ថ្នាក់ទី ៤ ទី៥ និងទី ៦ ៖

- គ្រូបង្រៀនម្នាក់ ទទួលខុសត្រូវគ្រប់ផ្នែកបង្រៀនសិស្សមួយថ្នាក់ក្នុងថេរៈវេលាមួយមួយពេលនៃកាលវិភាគប្រចាំថ្ងៃនៅក្នុងគ្រឹះស្ថានសិក្សា គឺមួយថ្ងៃបង្រៀន ៥(ប្រាំ) ម៉ោងកន្លះសិក្សា និង៥(ប្រាំ) ថ្ងៃក្នុងមួយសប្តាហ៍ ឬបង្រៀន ២៥(ម្ភៃប្រាំ)ម៉ោង សិក្សាក្នុងមួយសប្តាហ៍ នៅពេលព្រឹក ឬនៅពេលរសៀល
- ក្រៅពីរយៈពេលដែលត្រូវបំពេញសម្រាប់ការបង្រៀន គ្រូបង្រៀន ត្រូវបំពេញការងារពាក់ព័ន្ធសម្រាប់ថ្នាក់រៀនដែលខ្លួនទទួលបន្ទុកក្នុងក្របខ័ណ្ឌនៃរយៈពេលដែលបានកំណត់ក្នុងមាត្រា ៥ និងមាត្រា ៦នៃអនុក្រឹត្យនេះ ។

**មាត្រា ៨.**

មន្ត្រីរាជការទទួលបន្ទុកការងាររដ្ឋបាល ត្រូវបំពេញការងារអនុវត្តចំនួនថេរវេលាដែលមានកំណត់ក្នុងមាត្រា ៥នៃអនុក្រឹត្យនេះ ។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំ សេចក្តីណែនាំអំពីប្រភេទការងារ និងបែបបទនៃ ការបំពេញការងាររដ្ឋបាល ដើម្បីធានា ឱ្យមាននិរន្តរភាព និងប្រសិទ្ធភាពនៃដំណើរការរដ្ឋបាល នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ ។

## ជំពូកទី ៣
## បែបបទនិងនីតិវិធីនៃការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា

**មាត្រា ៩.**

ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវអនុវត្តក្នុងគ្រឹះស្ថានបឋមសិក្សា ខ្វះមន្ត្រីរាជការជាគ្រូបង្រៀន ដើម្បីបំពេញការងារស្របតាមនិយាមកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវផ្តល់ជាអាទិភាពសម្រាប់បំពេញការងារបង្រៀនដើម្បីជំនួសការងារបង្រៀនតាមរយៈការអនុវត្តភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប ។

**មាត្រា ១០.**

គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវបំពេញភារកិច្ចដូចគ្រូបង្រៀនកម្រិតបឋមដែលមានក្របខ័ណ្ឌអនុលោមភារកិច្ចកំណត់ និងទទួលប្រាក់កម្រៃដូចមានកំណត់ក្នុងមាត្រា ២២ នៃ អនុក្រឹត្យនេះ ប៉ុន្តែពុំមានសិទ្ធិដូចមន្ត្រីរាជការជាគ្រូបង្រៀនទេ ។

**មាត្រា ១១.**

គណៈគ្រប់គ្រងសាលា ត្រូវរៀបចំផែនការប្រើប្រាស់មន្ត្រីរាជការ និងគ្រូបង្រៀនជាប់កិច្ចសន្យាប្រចាំឆ្នាំរបស់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ដោយពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយដាក់សំណើផែនការនេះមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ។ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយមន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត មុននឹងដាក់សំណើផែនការនីមួយៗរបស់រាជរដ្ឋាភិបាល ។

ផែនការប្រើប្រាស់មន្ត្រីរាជការ និងគ្រូបង្រៀនជាប់កិច្ចសន្យាប្រចាំឆ្នាំ ត្រូវពិនិត្យ និងអនុម័តក្នុងថវិកាប្រចាំឆ្នាំនីមួយៗរបស់រាជរដ្ឋាភិបាល ។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសេចក្តីណែនាំអំពីបែបបទ និងនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់មន្ត្រីរាជការ និងគ្រូបង្រៀនជាប់កិច្ចសន្យានៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ ។

**មាត្រា ១២.**

ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវជ្រើសរើសចេញពី ៖

- សិស្ស និស្សិត ដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ ឬបានរៀនចប់ថ្នាក់ទី១២ និងមានអាយុចន្លោះពី១៨ (ដប់ប្រាំបី) ឆ្នាំ ដល់ ៣៥ (សាមសិបប្រាំ) ឆ្នាំ
- គ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវបានផ្តល់អាទិភាពដល់ ៖

- បេក្ខជនដែលកំពុងរស់នៅក្នុងមូលដ្ឋានដែលខ្វះគ្រូបង្រៀន
- ជនពិការ និងស្រ្តី ។

គ្រូបង្រៀនជាប់កិច្ចសន្យាដែលត្រូវបានជ្រើសរើសថ្មី ត្រូវទទួលការបំប៉នរយៈពេលខ្លីដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡាផ្នែកគរុកោសល្យ និងការងាររដ្ឋបាល ។

ក្នុងករណីក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីត្រូវការជ្រើសរើសមន្រ្តីរាជការក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ក្រសួងត្រូវធ្វើការប្រឡងជ្រើសរើសដោយផ្តល់អាទិភាពជាចម្បងដល់គ្រូបង្រៀនជាប់កិច្ចសន្យាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- សិស្ស និស្សិត ដែលត្រូវបានជ្រើសរើស និងបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈណាមួយរយៈពេលយ៉ាងយោច ៣(បី)ឆ្នាំជាប់ៗគ្នាបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន និង
- កំពុងបង្រៀននៅទីតាំងគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលខ្វះគ្រូបង្រៀន ។

**មាត្រា ១៣.**

ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវអនុវត្តដោយគណៈកម្មការដឹកនាំដោយមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្ត និងមានការចូលរួមពីតំណាងមន្ទីរមុខងារសាធារណៈរាជធានីខេត្ត ។

គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវប្រកាសទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត បន្ទាប់ពីទទួលបានទិដ្ឋាការពីមន្ទីរមុខងារសាធារណៈរាជធានី ខេត្តពាក់ព័ន្ធ។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសេចក្តីណែនាំអំពីបែបបទ និងនីតិវិធីនៃការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា ។

## ជំពូកទី ៤
## ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួបសម្រាប់មន្រ្តីរាជការ

**មាត្រា ១៤**

ភារកិច្ចបន្ថែម ត្រូវអនុញ្ញាត និងអនុវត្តចំពោះគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលចំនួនមន្រ្តីរាជការជាគ្រូបង្រៀនមិនឆ្លើយតបនឹងនិយាមផលធៀបសិស្សថ្នាក់ក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ កំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ១៥.**

ភារកិច្ចបន្ថែម ត្រូវបានប្រគល់បន្ថែមឱ្យមន្រ្តីរាជការជាគ្រូបង្រៀនម្នាក់ក្នុងលក្ខខណ្ឌដូចខាងក្រោម

- គ្រូបង្រៀននោះ បានបំពេញភារកិច្ចកំណត់ពេញលេញ ផ្អែកលើចំនួនម៉ោងសម្រាប់ថ្នាក់ក្នុងកម្រិតនីមួយៗដូចមានចែងក្នុងមាត្រា ៧នៃអនុក្រឹត្យនេះ
- សេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀន ឱ្យមានប្រសិទ្ធភាព
- ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបាន ។

**មាត្រា ១៦.**

ភារកិច្ចបន្ថែម ត្រូវបានប្រគល់បន្ថែម ឱ្យមន្រ្តីរាជការបំពេញការងាររដ្ឋបាលម្នាក់ក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- មន្រ្តីរាជការបំពេញការងាររដ្ឋបាលនោះ បានបំពេញភារកិច្ចកំណត់ពេញលេញ ផ្អែកលើចំនួនម៉ោងកំណត់ដូចមានចែងក្នុងមាត្រា ៥ និងមាត្រា ៨នៃអនុក្រឹត្យនេះ

- សេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀន ឱ្យមាននិរន្តរភាព
- ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការគ្រូបង្រៀនមិនអាចអនុវត្តបាន ។

**មាត្រា ១៧.**

មន្ត្រីរាជការដែលទទួលភារកិច្ចបន្ថែម ត្រូវបំពេញ ៖

- ភារកិច្ចកំណត់របស់ខ្លួនឱ្យបានពេញលេញ
- ភារកិច្ចបន្ថែម និងធ្វើការរដ្ឋបាលគ្រប់យ៉ាងសម្រាប់ថ្នាក់រៀន ប្រើពេលបង្រៀនសិស្សតាមកាលវិភាគច្រើនជាងលើសមន្ត្រីរាជការបំពេញការងារបង្រៀន ដែលបំពេញភារកិច្ចកំណត់ទូទៅដែលបង្រៀនតែមួយថ្នាក់ ឬលើសមន្ត្រីរាជការបំពេញការងាររដ្ឋបាលដែលបំពេញភារកិច្ចកំណត់ទូទៅ

**មាត្រា ១៨**

ភារកិច្ចថ្នាក់គួប ត្រូវបានអនុវត្តក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- ការខ្វះបន្ទប់រៀនសម្រាប់ធានាសេវាបង្រៀនដល់សិស្សនៅកម្រិតថ្នាក់ណាមួយ ឬ
- ការខ្វះគ្រូបង្រៀនសម្រាប់សិស្សនៅកម្រិតថ្នាក់ណាមួយ ហើយការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបាន ឬ
- ការខ្វះបន្ទប់រៀន និងចំនួនសិស្សមិនគ្រប់តាមនិយាមកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់បង្កើតថ្នាក់រៀនមួយថ្នាក់ដោយឡែក ឬ
- ការខ្វះគ្រូបង្រៀន និងចំនួនសិស្សមិនគ្រប់តាមនិយាមកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬ
- គ្រឹះស្ថានបឋមសិក្សាសាធារណៈនោះ មិនគ្រប់កម្រិត ។

**មាត្រា ១៩.**

ភារកិច្ចថ្នាក់គួប ត្រូវបានប្រគល់ឱ្យមន្ត្រីរាជការជាគ្រូបង្រៀនម្នាក់ក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- គ្រូបង្រៀននោះ បានបំពេញកាតព្វកិច្ចបង្រៀនផ្អែកតាមចំនួនម៉ោងបង្រៀនកំណត់សម្រាប់ថ្នាក់ក្នុងកម្រិតនីមួយៗ ដូចមានចែងក្នុងមាត្រា ៧នៃអនុក្រឹត្យនេះ
- សេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀនឱ្យមាននិរន្តរភាព
- ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបាន ។

**មាត្រា ២០.**

ភារកិច្ចថ្នាក់គួប ត្រូវបានប្រគល់ឱ្យមន្ត្រីរាជការបំពេញការងាររដ្ឋបាលម្នាក់ក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- មន្ត្រីរាជការបានបំពេញភារកិច្ចកំណត់ពេញលេញ ផ្អែកលើចំនួនម៉ោងកំណត់ដូចមានចែងក្នុងមាត្រា ៥ និងមាត្រា ៨នៃអនុក្រឹត្យនេះ
- សេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀនឱ្យមាននិរន្តរភាព
- ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការជាគ្រូបង្រៀនមិនអាចអនុវត្តបាន ។

**មាត្រា ២១.**

មន្ត្រីរាជការដែលទទួលភារកិច្ចថ្នាក់គួប ត្រូវបំពេញ ៖

- ភារកិច្ចថ្នាក់គួប និងធ្វើការរដ្ឋបាលគ្រប់យ៉ាងសម្រាប់ថ្នាក់រៀន ប្រើពេលបង្រៀនសិស្សតាមកាលវិភាគច្រើនជាងលើសមន្ត្រីរាជការបំពេញការងារបង្រៀនដែលបំពេញភារកិច្ចកំណត់ទូទៅដែលបង្រៀនតែមួយថ្នាក់ ឬលើសមន្ត្រីរាជការបំពេញការងាររដ្ឋបាលដែលបំពេញភារកិច្ចកំណត់ទូទៅ ។

## ជំពូកទី ៥

## ប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការដែលបានអនុវត្តភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប

**មាត្រា ២២.**

គ្រូបង្រៀនជាប់កិច្ចសន្យា ដែលត្រូវបានជ្រើសរើសសម្រាប់ការបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ ផ្អែកលើបទបញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវបានផ្តល់ប្រាក់កម្រៃប្រចាំខែចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ច ដូចខាងក្រោម ៖

- ស្មើនឹង ៨០% (ប៉ែតសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋម ដែលទើបត្រូវបានជ្រើសរើសថ្មីចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាដែលបានជ្រើសរើសពីសិស្ស និស្សិត
- ស្មើនឹង ៩០% (កៅសិបភាគរយ) នៃបៀវត្សសរុប ប្រចាំខែ នៃបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋម ដែលទើបត្រូវបានជ្រើសរើសថ្មីចំពោះគ្រូបង្រៀនជាប់កិច្ចសន្យា ដែលបានជ្រើសរើសពីគ្រូបង្រៀនចូលនិវត្តន៍គ្រប់ប្រភេទក្របខណ្ឌ ។

**មាត្រា ២៣**

មន្ត្រីរាជការជាគ្រូបង្រៀន ឬមន្ត្រីរាជការដែលបំពេញការងាររដ្ឋបាល នៅគ្រប់ប្រភេទក្របខ័ណ្ឌដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចបំពេញបន្ថែមក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវបានផ្តល់ប្រាក់កម្រៃភារកិច្ចបន្ថែមប្រចាំខែ ស្មើនឹងបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ច ។

**មាត្រា ២៤.**

មន្ត្រីរាជការជាគ្រូបង្រៀន ឬមន្ត្រីរាជការដែលបំពេញការងាររដ្ឋបាល នៅគ្រប់ប្រភេទក្របខណ្ឌដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចបន្ថែមក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវបានផ្តល់ប្រាក់កម្រៃភារកិច្ចបន្ថែមប្រចាំខែ ចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ច ដូចខាងក្រោម ៖

- ស្មើនឹង ៦០%(ហុកសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មីចំពោះថ្នាក់គួបដែលមានពីរកម្រិត
- ស្មើនឹង ៨០% (ប៉ែតសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារអប់រំមន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មីចំពោះថ្នាក់គួបដែលមានបីកម្រិត ។

**មាត្រា ២៥.**

ប្រាក់កម្រៃដែលត្រូវផ្តល់ឱ្យគ្រូបង្រៀនជាប់កិច្ចសន្យា មន្ត្រីរាជការដែលអនុវត្តភារកិច្ចបន្ថែម និងមន្ត្រីរាជការដែលអនុវត្តភារកិច្ចថ្នាក់គួប ត្រូវអនុវត្តតាមតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ ។

## ជំពូកទី ៦

## ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការងារបង្រៀនតាមកិច្ចសន្យា និងការអនុវត្តភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប

**មាត្រា ២៦.**

គណៈគ្រប់គ្រងសាលា ត្រូវពិនិត្យ គ្រប់គ្រង និងចាត់ចែងសេវាបង្រៀន ឱ្យមានប្រសិទ្ធភាពក្នុង

គ្រឹះស្ថានបឋមសិក្សាសាធារណៈរបស់ខ្លួន ផ្អែកលើភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់គួប និងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា អនុលោមនិយាមកំណត់ក្នុងអនុក្រឹត្យនេះ និងនិយាមស្តីពីការប្រើប្រាស់បុគ្គលិកអប់រំកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

ការជ្រើសរើស និងការចាត់តាំងគ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការ ឱ្យអនុវត្តភារកិច្ចបន្ថែម ឬភារកិច្ចថ្នាក់គួប ត្រូវពិនិត្យនិងរៀបចំដោយគណៈគ្រប់គ្រងសាលា ។

នាយក ឬនាយិកាសាលាក្នុងនាមគណៈគ្រប់គ្រងសាលា ត្រូវលើកសំណើអំពីការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាឬមន្ត្រីរាជការ ឱ្យអនុវត្តភារកិច្ចបន្ថែមឬភារកិច្ចថ្នាក់គួបមកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីពិនិត្យនិងសម្រេចតាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ផ្អែកលើផែនការប្រចាំឆ្នាំដែលទទួលការអនុម័តក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរួបហើយ ។

**មាត្រា ២៧.**

គណៈគ្រប់គ្រងសាលា ត្រូវគ្រប់គ្រងនិងចាត់ចែងការងារ ព្រមទាំងត្រូវមានគណនេយ្យភាពនិងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការធានានូវប្រសិទ្ធភាពនៃការអនុវត្តភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់គួបការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា និងការបើកផ្តល់ប្រាក់កម្រៃនៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ។

ប្រធានការិយាល័យអប់រំ និងកីឡាក្រុង ស្រុក ខណ្ឌ និងប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវក្នុងការត្រួតពិនិត្យនិងណែនាំការបំពេញការងាររបស់គណៈគ្រប់គ្រងសាលាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២៨.**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃអំពីស្ថានភាពនៃការគ្រប់គ្រង និងការចាត់ចែងការបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ នៅរៀងរាល់ដំណាច់ឆ្នាំសិក្សានីមួយៗ ឬផ្អែកលើភាពចាំបាច់នៃការងារក្នុងគោលដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្សគាំទ្រដល់សេវាបង្រៀន ។

## **ជំពូកទី ៧**
## **អវសានប្បញ្ញត្តិ**

**មាត្រា ២៩.**

អនុក្រឹត្យលេខ ៦៩អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការកម្រិតភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់គួប និងប្រាក់កម្រៃសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន